ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

អបអរសាទរខួប

៥ ឆ្នាំ

ប្រតិបត្តិការ
២០១៦ - ២០២០

# របាយការណ៍ប្រចាំឆ្នាំ
# ២០២០

# តារាងមាតិកា

ទំព័រ


សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ០៣
សាររបស់នាយកប្រតិបត្តិ ០៥
ផែនទីតំបន់ប្រតិបត្តិការ ០៧
ប្រតិបត្តិការសំខាន់ៗ ០៩
របាយការណ៍ហិរញ្ញវត្ថុសង្ខេប ១០
បច្ចុប្បន្នភាពស្ថិតិបុគ្គលិក ១១
សមិទ្ធផលសំខាន់ៗ ១៣

អំពីហ្វូតាបា

ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា ១៨
ប្រវត្តិសង្ខេបរបស់ ហ្វូតាបា ១៩
ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល ២១
ស្លាកសញ្ញារបស់ ហ្វូតាបា ២៣

អភិបាលកិច្ច

ម្ចាស់ភាគហ៊ុន និងដើមទុន ២៦
រចនាសម្ព័ន្ធ ២៨
ក្រុមប្រឹក្សាភិបាល ២៩
គណៈគ្រប់គ្រង ៣១

សមិទ្ធផលអាជីវកម្ម

សមិទ្ធផលឥណទានតាមវិស័យ ៣៨
សមិទ្ធផលឥណទានតាមផលិតផល ៤០
ចំណាត់ថ្នាក់ប្រភេទឥណទាន ៤២
ចំណាត់ថ្នាក់ប្រភេទផលិតផល ៤៣

ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម ៤៦
សវនកម្មផ្ទៃក្នុង ៤៧

## ផលិតផល ហ្វូតាបា


| | |
|---|---|
| ឥណទានអាជីវកម្ម | ៥១ |
| ឥណទានគេហដ្ឋាន | ៥១ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៥២ |
| ឥណទានកសិកម្ម | ៥២ |
| ឥណទានសិក្សា | ៥៣ |
| ឥណទានបុគ្គលិក | ៥៣ |
| ឥណទាននិយោជិត | ៥៤ |


## ការអភិវឌ្ឍន៍បុគ្គលិក


| | |
|---|---|
| ការបណ្តុះបណ្តាលខាងក្នុង | ៥៦ |
| ការបណ្តុះបណ្តាលខាងក្រៅ | ៥៨ |


## របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មឯករាជ្យ


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៦០ |
| របាយការណ៍របស់សវនករឯករាជ្យ | ៦៣ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦៥ |
| របាយការណ៍លទ្ធផលលម្អិត | ៦៦ |
| របាយការណ៍បម្រែបម្រួលមូលធន | ៦៧ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៦៨ |


## ដៃគូសហប្រតិបត្តិការរបស់ ហ្វូតាបា


| | |
|---|---|
| ដៃគូ | ៦៩ |
| ម្ចាស់ជំនួយ | ៧០ |

# សារលោកប្រធានក្រុមប្រឹក្សាភិបាល



លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

តាមការព្យាករណ៍របស់ធនាគារពិភពលោកបានបង្ហាញថា នៅក្នុងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានការធ្លាក់ចុះក្នុងរង្វង់ ២% សម្រាប់មូលហេតុចម្បងដែលធ្វើឱ្យមានការធ្លាក់នេះ ដោយសារតែមានផលប៉ះពាល់ពីការរាតត្បាតជាសកលរបស់មេរោគកូវីត-១៩។ ចំពោះផលប៉ះពាល់នេះ បានធ្វើឱ្យការរំខានដល់ការផ្គត់ផ្គង់កម្លាំងពលកម្ម តម្រូវការអ្នកប្រើប្រាស់ ការធ្វើពាណិជ្ជកម្មជាសកល និងក្នុងស្រុក ការធ្វើដំណើរ និងទេសចរណ៍ ក៏ដូចជាធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងលើទំនុកចិត្តរបស់វិនិយោគិនក្នុងការពង្រីកអាជីវកម្មរបស់ខ្លួន។

កត្តាសំខាន់ៗដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជារួមមាន វិស័យនាំចេញទំនិញ ទេសចរណ៍ និងសំណង់។ ផលប៉ះពាល់នៃមេរោគកូវីត-១៩នេះ គឺបានបញ្ឈប់ការសាងសង់ និងអចលនទ្រព្យដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគបរទេស។ ដោយសារតែការរឹតត្បិតនៃការធ្វើដំណើរ និងការបិទទ្វារទេសចរណ៍ បានធ្វើឱ្យបដិសណ្ឋារកិច្ចអន្តរជាតិរបស់កម្ពុជាត្រូវបានដួលរលំ។ ម្យ៉ាងវិញទៀត ផលប៉ះពាល់នេះបានធ្វើឱ្យការផ្គត់ផ្គង់ និងតម្រូវការសកលរបស់វិស័យសម្លៀកបំពាក់ និងស្បែកជើង ដែលជាវិស័យនាំចេញទំនិញដ៏សំខាន់របស់កម្ពុជាត្រូវបានធ្លាក់ចុះផងដែរ។

វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ មានតួនាទីយ៉ាងសំខាន់ណាស់ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ចឱ្យកាន់តែប្រសើរ។ បើយោងតាមព័ត៌មានស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុ គិតត្រឹមខែកញ្ញា ឆ្នាំ២០២០ របស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញថា ធនាគារពាណិជ្ជមានចំនួន ៥២ ធនាគារឯកទេសមានចំនួន ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ០៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៧៥ ប្រតិបត្តិករឥណទានជនបទមានចំនួន ២៤៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ១៥ ក្រុមហ៊ុនសវនកម្មមានចំនួន ១០ អ្នកដំណើរការតតិយភាគីមានចំនួន ០៤ គ្រឹះស្ថានផ្តល់សេវាទូទាត់មាន

ចំនួន ២៤ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាមានចំនួន ០១ និងការិយាល័យតំណាងធនាគារបរទេសមានចំនួន ០៦ និង អាជីវករប្តូរប្រាក់មានចំនួន ២.៨០៥។ ក្នុងនោះគិតត្រឹមខែកញ្ញា ឆ្នាំ២០២០ រូបិយវត្ថុទូទៅបានបន្តកើនឡើងដល់ ១៣២.៦១៣,៦ ប៊ីលានរៀល ដែលមានទ្រព្យសកម្មក្នុងស្រុកសុទ្ធនៃវិស័យធនាគារមានចំនួន ៦៤.៥៥២,៩ ប៊ីលានរៀល និងទ្រព្យសកម្មបរទេសសុទ្ធនៃវិស័យធនាគារមានចំនួន ៦៨.០៦០,៧ ប៊ីលានរៀល។ ចំណុចនេះ យើងអាចមើល ឃើញថា នៅតែមានការបន្តបណ្តាក់ទុនបន្ថែមពីអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកមកលើវិស័យធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

ទោះបីជាការព្យាករណ៍សេដ្ឋកិច្ចរបស់កម្ពុជានៅឆ្នាំ២០២០ នឹងមានការធ្លាក់ចុះនៅរង្វង់ ២% ក៏ដោយ ប៉ុន្តែការព្យាករណ៍ នោះក៏បានបង្ហាញដែលថានៅឆ្នាំ២០២១ នឹងការកើនឡើង ៤% វិញ។ កត្តាដែលធ្វើឱ្យសេដ្ឋកិច្ចមានការកើនឡើង នោះ ដោយសារតែជំងឺរាតត្បាតជាសកលនៃមេរោគកូវីត-១៩ នឹងមានការថយចុះបន្តិចម្តងៗ ដូចនេះធ្វើឱ្យសេដ្ឋកិច្ចក្នុងស្រុក របស់កម្ពុជានឹងវិលទៅរកភាពប្រក្រតីជាបណ្តើរៗ រួមទាំងការធ្វើដំណើរ និងទេសចរណ៍ផងដែរ។ ម៉្យាងទៀត ការចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន (CCFTA) នឹងត្រូវចូលជាធរមាននៅឆ្នាំ២០២១ នឹងជួយលើក កម្ពស់ការវិនិយោគក្នុងស្រុក និងពាណិជ្ជកម្មក្នុងតំបន់។ លើសពីនេះទៀត អត្ថប្រយោជន៍ពីការក្លាយជាសមាជិកនៃភាព ជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ដែលជាតំបន់ពាណិជ្ជកម្មសេរីធំបំផុតនៅលើពិភពលោកដែលត្រូវ បានចុះហត្ថលេខានៅខែវិច្ឆិកា ឆ្នាំ២០២០ នឹងចាប់ផ្តើមធ្វើឱ្យមានអ្នកវិនិយោគហូរចូលមកកម្ពុជាជាបណ្តើរៗចាប់តាំងពី ដើមឆ្នាំ២០២១។

ដោយសារតែមានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ-១៩ នៅឆ្នាំ២០២០ នេះ បានធ្វើឱ្យកម្រិតហានិភ័យ នៃ ផលបត្រឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុមានការកើនឡើង រួមទាំងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ីផងដែរ។ ប៉ុន្តែស្ថិតក្នុងកាលៈទេសៈនេះ យើងក៏អាចរក្សាបានកម្រិតហានិភ័យនៃផលបត្រឥណទានក្រោម ៥.០% និងអតិថិជន យឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្រោម ០.៣%។ ជាមួយនឹងលទ្ធផលនេះ បានបង្ហាញពីការចូលរួមសហការពីបុគ្គលិក គ្រប់ផ្នែក និងពិសេសផ្នែកឥណទានផ្ទាល់ ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយឱ្យបានទាន់ពេល វេលា។ ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុករបស់ភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាល យើងនឹង រៀបចំផែនការរំកិលប្រចាំឆ្នាំបន្តបន្ទាប់ទៀត ក្នុងគោលបំណងពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើ វិសាលភាព ទីផ្សារឱ្យបានទូលំទូលាយ អាស្រ័យលើការដាក់បញ្ចូលដើមទុនរបស់ម្ចាស់ភាគទុនិកបន្ថែម និងម្ចាស់កម្ចីនានា ដើម្បី ឆ្លើយតបទៅនឹងកំណើន នៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេល បច្ចុប្បន្ន និងអនាគត។

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជន ភាគទុនិកជប៉ុនរបស់យើងខ្ញុំ នៅតែ មានសុច្ឆន្ទៈចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សជំនាន់ក្រោយនៃព្រះរាជាណាចក្រកម្ពុជា នាយកប្រតិបត្តិ ជំនួយការ នាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការគាំទ្រ និងការខិតខំ ប្រឹងប្រែងក្នុងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។ ជាពិសេសចំពោះធនាគារជាតិនៃកម្ពុជា ដែលតែងតែ ផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ដើម្បីចាត់ចែងនូវរាល់សកម្មភាពការងារទាំងអស់ ប្រកបដោយតម្លា ភាពរហូតមកដល់ពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ វិបុលសុខ ចូរកើតមានដល់លោកអ្នក និងក្រុមគ្រួសារ សេចក្តីចម្រើនមានបាន ជោគជ័យគ្រប់ភារកិច្ចការងារ ជានិច្ចនិរន្តតរៀងទៅ។

លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

# សារលោកនាយកប្រតិបត្តិ



លោក Junichi SASAKI
នាយកប្រតិបត្តិ

ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព!

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី បានទទួល អាជ្ញាប័ណ្ណជាស្ថាប័នហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបសកម្មភាពអាជីវកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ប្រកបអាជីវកម្មជាផ្លូវការមកឱ្យគ្រឹះស្ថាន ជំនួសអាជ្ញាបណ្ណដែលមានកំណត់រយៈពេល ៣ឆ្នាំ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ យើងបានបើកដំណើរការប្រតិបត្តិការ ដែលមានការិយាល័យសាខាចំនួន ០៤ ខេត្ត - រាជធានី រួមមានទីស្នាក់ការកណ្តាល (រួមជាមួយសាខាការិយាល័យកណ្តាល) សាខាខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ជាមួយនឹងអតិថិជនដែលបាន និងកំពុងទទួលកម្ចីមានសរុប ៨០០ នាក់ ទន្ទឹមនឹងមានការកើនឡើងផលបត្រឥណទានសរុបដល់ ១៤.៤០៩.២១៩ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងមន្រ្តីឥណទានចំនួន ១៩នាក់។

នៅក្នុងឆ្នាំ២០២០ ការរាតត្បាតជាសកលរបស់មេរោគកូវីត-១៩ បានធ្វើឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចជុំវិញពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ផលប៉ះពាល់នេះបានធ្វើឱ្យ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុីមានអត្រាហានិភ័យផលបត្រឥណទាន កើនឡើងដល់ ៤.៨ ភាគរយ និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីឡើងដល់ ០.២៧ ភាគរយ។

ទោះបីគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មិនទាន់មានការិយាល័យប្រតិបត្តិការឱ្យបានទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា ក៏ចក្ខុវិស័យរបស់យើងខ្ញុំ គឺនឹងធ្វើខ្លួនឱ្យក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងពេលបច្ចុប្បន្ន និងពេលអនាគតតាមរយៈការធ្វើឲ្យមានលំនឹងស្ថិរភាព តម្លាភាពលើផ្នែកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា និងផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលនឹង ពង្រីកតំបន់ប្រតិបត្តិឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងទៀត ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែបន្តអនុវត្តផែនការគោល និងផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើ វិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

កន្លងមក ដើម្បីបំពេញតម្រូវការរបស់អតិថិជន គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ីបានបង្កើតផលិតផល សេវាហិរញ្ញវត្ថុជាច្រើនដែលរួមមាន ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ ឥណទានបុគ្គលិក ឥណទានសម្រាប់ការសិក្សា និងឥណទាននិយោជិត។ ចំពោះឥណទានបុគ្គលិក និងឥណទានសម្រាប់ការសិក្សា ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់ទាបបំផុត ជាមួយនឹងសេវាល្អឥតខ្ចោះដែលមិនធ្លាប់មាន ក្នុងគោលដៅចូលរួមលើកស្ទួយផ្នែកសង្គម គាំទ្រជីវភាពគ្រួសាររបស់បុគ្គលិក និងអភិវឌ្ឍវិស័យធនធានមនុស្ស។ តទៅមុខទៀត គ្រឹះស្ថានរបស់យើងខ្ញុំ នឹងរិះរកវិធីក្នុងការផ្តល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ និងថ្មីទាំងអស់។

ទន្ទឹមនឹងការបំពេញតម្រូវការអតិថិជន យើងក៏បានយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនដើម្បីឱ្យការប្រតិបត្តិមានភាពរឹងមាំដោយផ្តោតលើការបណ្តុះបណ្តាលចំណេះជំនាញបុគ្គលិក ការកែសម្រួលរចនាសម្ព័ន្ធ និងបច្ចុប្បន្នភាពលើគោលការណ៍នីតិវិធីនានា ព្រមទាំងត្រូវប្រតិបត្តិតាមច្បាប់ ឬបទប្បញ្ញត្តិដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធ។

តាមការរំពឹងទុក ការរីករាលដាលនឹងមានការថយចុះនៅក្នុងឆ្នាំ២០២១ ហើយសេដ្ឋកិច្ចកម្ពុជា និងពិភពលោកនឹងមានដំណើរការល្អប្រសើរឡើងវិញ។ ម្យ៉ាងទៀត យើងសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានយើងខ្ញុំនឹងក្លាយជាមាគ៌ា សម្រាប់អ្នកជំនាន់ក្រោយកម្ពុជា ដែលសម្រេចយកភាពត្រឹមត្រូវ ស្មើគ្នា និងរក្សាឱ្យបាននូវតម្លាភាព ជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិនៃប្រទេសជប៉ុនដែលយើងខ្ញុំអាចចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។

ដើម្បីឱ្យ "សុបិនអតិថិជនក្លាយជាការពិត" យើងខ្ញុំរីករាយស្វាគមន៍សហការក្នុងការផ្តល់សេវាហិរញ្ញវត្ថុយ៉ាងកក់ក្តៅ និងជាទីទុកចិត្តបំផុតជូនអតិថិជនទាំងអស់ និងគ្រប់ពេលវេលាដែលត្រូវការ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន ភាគទុនិកជប៉ុន ក្រុមប្រឹក្សាភិបាល ជំនួយការនាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់ ដែលតែងតែគាំទ្រ និងការខិតខំប្រឹងប្រែងក្នុងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន ក៏ដូចជាធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ។

សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។

លោក Junichi SASAKI
នាយកប្រតិបត្តិ

# ផែនទីតំបន់ប្រតិបត្តិការ




**១១** ចំនួនខេត្តប្រតិបត្តិ

**៤២** ចំនួនស្រុកប្រតិបត្តិ

**១៥៩** ចំនួនឃុំប្រតិបត្តិ

**៣៦៥** ចំនួនភូមិប្រតិបត្តិ

## ១ ការិយាល័យកណ្តាល និងសាខាការិយាល័យកណ្តាល

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ២៣ ២២៤ ៣៣៣ / (៨៥៥) ៧០ ៣១២ ៣៣៣

## ២ សាខាខណ្ឌទួលគោក

ផ្ទះលេខ២៥ ផ្លូវលេខ៥៩៨ ភូមិ១ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ៧០ ៣១៧ ៣៣៣

## ៣ សាខាខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ៧៨ក ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ៧០ ៣១៦ ៣៣៣

## ៤ សាខាក្រុងច្បារមន

ផ្ទះលេខ៤ ផ្លូវជាតិលេខ៤ ភូមិសំបួរ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ៧០ ៣១៤ ៣៣៣

# ប្រតិបត្តិការសំខាន់ៗ

| បរិយាយ | ៣១ ធ្នូ ២០២០ |
|---|---|
| ចំនួនការិយាល័យសាខា | ៤ |
| ចំនួនបុគ្គលិកសរុប | ៧៧ |
| ចំនួនមន្ត្រីឥណទានសរុប | ១៩ |
| ចំនួនរាជធានី-ខេត្តប្រតិបត្តិការ | ១១ |
| ចំនួនស្រុកប្រតិបត្តិការ | ៤២ |
| ចំនួនឃុំប្រតិបត្តិការ | ១៥៩ |
| ចំនួនភូមិប្រតិបត្តិការ | ៣៦៥ |
| ចំនួនអតិថិជនឥណទានសរុប | ៨០០ |
| សម្ពាធឥណទានសរុប (គិតជា ដុល្លារ) | ១៤.៤០៩.២១៩ |
| សម្ពាធឥណទានមានហានីភ័យសរុប (PAR %) | ៤.៨០% |
| សម្ពាធឥណទានសម្រាប់មន្ត្រីឥណទានម្នាក់ (គិតជា ដុល្លារ) | ៧៥៨.៣៨០ |
| សម្ពាធឥណទានសម្រាប់បុគ្គលិកម្នាក់ (គិតជា ដុល្លារ) | ១៨៧.១៣៣ |
| សម្ពាធឥណទានគិតជាមធ្យម (គិតជា ដុល្លារ) | ១៨.០១២ |
| **ទ្រព្យសកម្មសរុប (គិតជា ដុល្លារ)** | **១៥.១២៤.៣៤៦** |

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## របាយការណ៍សមតុល្យ

៣១ ធ្នូ ២០២០
(ធ្វើសវនកម្មរួច), (គិតជា ដុល្លារ)

### ទ្រព្យសកម្មសរុប

| | |
|---|---|
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៦៤៧.៤៧៧ |
| សម្ភាធឥណទានបានផ្ដល់ជូនអតិថិជនសរុប -សុទ្ធ | ១៤.២៣៨.៩៥៩ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ១០៧.០៦៨ |
| ទ្រព្យសម្បត្តិផ្សេងៗ | ១៣០.៨៤២ |
| **សរុបទ្រព្យសកម្ម** | **១៥.១២៤.៣៤៦** |

### បំណុល

| | |
|---|---|
| បំណុលផ្សេងៗ និងសំវិធានធន | ១.៥៤១.៥៤៩ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៥.៥៣០.៥១៣ |
| **បំណុលសរុប** | **៧.០៧២.០៦២** |

### មូលធនភាគទុនិក

| | |
|---|---|
| មូលធនភាគទុនិកសរុប | ៨.០៥២.២៨៤ |
| **សរុបបំណុល និងមូលធនភាគទុនិក** | **១៥.១២៤.៣៤៦** |

## របាយការណ៍ចំណូល និងចំណាយ

៣១ ធ្នូ ២០២០
(ធ្វើសវនកម្មរួច), (គិតជា ដុល្លារ)

| | |
|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ១.៨២៣.០៦៩ |
| ចំណាយប្រតិបត្តិការសរុប | ១.៣៤៦.០០៧ |
| **ប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធ** | **៤៧៧.០៦២** |

# បច្ចុប្បន្នភាពស្ថិតិបុគ្គលិក

គិតត្រឹមបំណាច់ឆ្នាំ២០២០នេះ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានបុគ្គលិកសរុបចំនួន ៧៧រូប (បុរស ៥៤រូប និងស្ត្រី ២៣រូប) មានការកើនឡើងចំនួន ០៣រូប។

ខាងក្រោមនេះគឺជាព័ត៌មានបុគ្គលិកសង្ខេបរបស់ ហ្វូតាបា៖

### ចំនួនបុគ្គលិកសរុប




### ចំនួនបុគ្គលិកតាមសាខា




### ភេទ




### ប្រភេទ



## កំណើនបុគ្គលិកប្រចាំត្រីមាស




## បម្រែបម្រួលបុគ្គលិកប្រចាំត្រីមាស




## បម្រែបម្រួលបុគ្គលិកពេញមួយឆ្នាំ



# សមិទ្ធផលសំខាន់ៗ

| ពិពណ៌នា | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១៣.៧៧៧.១៩០ | ១៤.៩១៨.១៣៤ | ១៥.១២៤.៣៤៦ |
| ផលប័ត្រឥណទានដុល | ១២.៨០៤.៨០៨ | ១៣.៥៤០.៤៩១ | ១៤.៤០៩.២១៩ |
| មូលធនភាគទុនិក | ៧.១១០.៤០៦ | ៧.៥៧៥.២២២ | ៨.០៥២.២៨៤ |
| ប្រាក់ចំណេញសុទ្ធ | ៥៨០.៣៨៩ | ៤៦៤.៨១៦ | ៤៧៧.០៦២ |
| ចំនួនអតិថិជនឥណទានសរុប | ៧៨០ | ៨១៩ | ៨០០ |
| ចំនួនសាខា | ៤ | ៤ | ៤ |
| ចំណាយប្រតិបត្តិការ / ផលប័ត្រឥណទាន | ៨% | ៩% | ៨% |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | - | - | ៤,៨០% |
| អនុបាតឥណទានលុបចេញពីបញ្ជី | - | - | ៣៨.៣៥៤ |
| អនុបាតសាធនភាព | ៥៣% | ៥២% | ៥៥% |
| អត្រាចំណេញពីទ្រព្យសកម្ម | ៤% | ៣% | ៣% |
| អត្រាចំណេញពីមូលធនភាគទុនិក | ៨% | ៦% | ៦% |

## ទ្រព្យសកម្មសរុប




## ផលប័ត្រឥណទានដុល



## មូលធនភាគទុនិក




## ប្រាក់ចំណេញសុទ្ធ





# អំពី ហ្វូតាបា

- ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
- ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
- ទស្សនៈវិស័យ  បេសកកម្ម និងតម្លៃស្នូល
- ស្លាកសញ្ញារបស់ ហ្វូតាបា



# ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននាចុងឆ្នាំ២០១៥ ដែលបានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ពីធនាគារជាតិនៃកម្ពុជា ក្រោមបេសកកម្ម និងទស្សនៈវិស័យដ៏ច្បាស់លាស់របស់ខ្លួន ដែលចង់ក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណជូនគ្រឹះស្ថាន **ហ្វូតាបា** រយៈពេល ៣ឆ្នាំបន្ថែមទៀត ក្រោយមកដោយមើលឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទាន និងបានកែសម្រួលលើចំណុចខ្វះខាតតាមអនុសាសន៍ នៃការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេច ផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន **ហ្វូតាបា**។ ចាប់តាំងពីឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & CO., LTD. (ជាក្រុមហ៊ុនជប៉ុន) ក៏បានក្លាយជាភាគទុនិកកាន់កាប់ភាគហ៊ុន ១00% របស់គ្រឹះស្ថាន **ហ្វូតាបា**។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ យើងមានបុគ្គលិកសរុបចំនួន ៧៧នាក់ ស្រីចំនួន ២៣នាក់ និងប្រុសចំនួន ៥៤នាក់ ដែលកំពុងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាចំនួន ០៤ខេត្ត-រាជធានី រួមមាន សាខាការិយាល័យកណ្តាល សាខាខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ចំពោះអតិថិនជនដែលបាននិងកំពុងទទួលកម្ចីមានសរុប ៨០០នាក់ ជាមួយនឹងផលបត្រឥណទានសរុប ១៤.៤០៩.២១៩ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងមន្ត្រីឥណទានចំនួន ១៩នាក់ ដែលមានការកើនឡើងក្នុងកម្រិតតិចតួច តែគ្រឹះស្ថាន **ហ្វូតាបា** នៅតែបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមាន និងភាពរីកចម្រើនទៅថ្ងៃអនាគត។ ជាពិសេសក្នុងអំឡុង ៤ឆ្នាំកន្លងមកពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទាន ក្នុងអត្រា ០.៤៦% និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា ០% ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ ដោយឡែកសម្រាប់ឆ្នាំ២០២០នេះ មានការកើនឡើងលើកម្រិតហានិភ័យ នៃផលបត្រឥណទានរហូតដល់អត្រា ៤.៨០% និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា ០.២៧% ដោយសារតែ មានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ-១៩។ ក្នុងស្ថានភាពនេះផងដែរ គ្រឹះស្ថាន **ហ្វូតាបា** បាននិងកំពុងផ្តល់ឥណទាន រៀបចំឡើងវិញជូនអតិថិជនក្នុងអត្រា ៦.៤០% បើធៀបនឹងអតិថិជនសរុប និងអត្រា ៧.៧០% បើធៀបនឹងផលបត្រឥណទានសរុប។

ចំពោះរបាយការណ៍ហិរញ្ញវត្ថុវិញ យើងឃើញថា គ្រឹះស្ថាន **ហ្វូតាបា** បានចំណាយពេលវេលាជាង ១ឆ្នាំ ទើបទទួលបានការចំណេញសុទ្ធរបស់ខ្លួនចាប់តាំងពីឆ្នាំ២០១៧ រហូតមក ហើយមានផលប៉ះពាល់ច្រើនពីការរីលរាលដាលនៃមេរោគកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏ការចំណេញសុទ្ធនៅបំណាច់ឆ្នាំ២០២០ នេះមានចំនួន ៤៧៧.០៦២ ដុល្លារអាមេរិក ដែលជាលទ្ធផលហិរញ្ញវត្ថុដ៏ល្អប្រសើរមួយ ក្នុងស្ថានភាពដែលលំបាក ហើយគ្រឹះស្ថាននៅតែបន្តប្រតិបត្តិការសកម្មភាពរបស់ខ្លួនដោយវិជ្ជមាន។

ជាផ្នែកមួយក្នុងការគាំទ្រដល់ការអភិវឌ្ឍលើការអប់រំ និងជីវភាពរបស់បុគ្គលិក គ្រឹះស្ថាន **ហ្វូតាបា** ក៏បានផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាបបំផុតលើឥណទានសិក្សា និងឥណទានបុគ្គលិក ដែលជាគោលដៅចម្បងរបស់ក្រុមប្រឹក្សាភិបាល នឹងម្ចាស់ភាគទុនិក ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តអនុវត្តផែនការគោល និងផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

# ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន ហ្វូតាបា

ដើមទុន

៧.០០០.០០០ ដុល្លារ

ចំនួនសាខា

៤ សាខា

- សាខាការិយាល័យកណ្ដាល
- សាខាខណ្ឌទួលគោក
- សាខាខណ្ឌពោធិ៍សែនជ័យ
- សាខាក្រុងច្បារមន

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្តីសុបិនរបស់ភាគទុនិកតាមរយៈគំនិតផ្ដួចផ្ដើម ព្រមទាំងការប្ដេជ្ញាចិត្តខ្ពស់ភាគទុនិកបានជម្នះនូវរាល់ឧបសគ្គទាំងឡាយ រហូតទទួលបានអាជ្ញាបណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

នៅដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មជាមួយនឹងដើមទុនដំបូង ១.០០០.០០០ ដុល្លារអាមេរិក ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យដ៏ត្រចះត្រចង់។ ជាមួយគ្នានេះផងដែរ ក្នុងឆ្នាំ២០១៦ នេះ ក្រុមហ៊ុន AZUMA & CO., LTD. ក៏បានក្លាយជាភាគទុនិកថ្មីរបស់ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន ដែលមានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាព ស្តង់ដាររស់នៅជូនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងបន្តអនុវត្តផែនការគោលរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃក្តីសុបិនរបស់ភាគទុនិក។ ជាក់ស្តែងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣) បន្ថែមទៀតនៅចុងឆ្នាំ២០១៦នេះ ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។ សាខាបើកថ្មីទាំងបី (៣) នោះ ត្រូវបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រងព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារ

ជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាប័ណ្ណរយៈពេល ៣ឆ្នាំបន្ថែមទៀត ហើយនាចុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន **ហ្វូតាចា** កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ យើងឃើញថា គ្រឹះស្ថាន **ហ្វូតាចា** មិនមានការបន្ថែមដើមទុន និងពង្រីកប្រតិបត្តិការសាខាទៀតទេចាប់ពីឆ្នាំ២០១៧ មកដល់ឆ្នាំ២០២០នេះ ដោយសារតែគ្រឹះស្ថាននៅរក្សាយុទ្ធសាស្ត្រ ក្នុងការពង្រឹងលើប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុង និងបង្កើនចំណេះជំនាញដល់បុគ្គលិក ជាពិសេស ខិតខំប្រឹងប្រែងរក្សាលទ្ធផលរបស់ខ្លួនឱ្យបានល្អប្រសើរក្នុងស្ថានភាពនៃការរីករាលដាលនៃមេរោគកូវីដ-១៩នេះ។

ថ្ងៃ១៦ ខែធ្នូ ឆ្នាំ២០១៥
ដើមទុនដំបូងចំនួន **១.០០០.០០០ ដុល្លារ**




ថ្ងៃ២៣ ខែធ្នូ ឆ្នាំ២០១៦
បន្ថែមដើមទុនចំនួន
**៥.០០០.០០០ ដុល្លារ**

ថ្ងៃ១៦ ខែមិថុនា ឆ្នាំ២០១៦
បន្ថែមដើមទុនចំនួន **១.០០០.០០០ ដុល្លារ**

## ការវិវឌ្ឍន៍នៃដើមទុន



# ទស្សនៈវិស័យ និងបេសកកម្ម

## ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជន នាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី។

## បេសកកម្ម

ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុត ទៅកាន់សហគ្រាស ខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជន នាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្តីសុបិនរបស់ពួកគាត់ ជាមួយអនាគតដ៏ប្រសើរ។

# តម្លៃស្នូល

សុចរិតភាព

០១

មនុស្សជាតិ

០២

ការតម្រង់ទិស

០៣

ការប្រកួតប្រជែង

០៤

សេចក្តីក្លៀវក្លា

០៥

# ស្លាកសញ្ញារបស់ ហ្វូតាបា

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។ ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគតដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ថែទាំ និងដាក់ជីយ៉ាងល្អិតល្អន់របស់យើងទាំងអស់គ្នា។

ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនលើវិស័យហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា នាពេលអនាគតខាងមុខ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ធានាឲ្យបាននូវស្ថិរភាព និងផ្តល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ឬ ក៏ធនាគារ **ហ្វូតាបា** ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូចរីកលូតលាស់ទៅជាដើមឈើដ៏ធំនាពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុន ដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្តីត្រូវការរបស់អតិថិជនយើងខ្ញុំ។

## ពណ៌

ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថានភាព សុខុដុម រវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន នាពេលបច្ចុប្បន្ន និងតទៅអនាគតសម្រាប់ជំនាន់ក្រោយ។

## ពាក្យស្លោក

**សុបិនក្លាយជាការពិត**


អបអរសាទរខួប
៥ ឆ្នាំ
ប្រតិបត្តិការ
២០១៦ - ២០២០
ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

# អភិបាលកិច្ច

- ម្ចាស់ភាគទុនិក និងដើមទុន
- រចនាសម្ព័ន្ធ
- ក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

អបអរសាទរខួប

៥ ឆ្នាំ

ប្រតិបត្តិការ

២០១៦ - ២០២០

# ម្ចាស់ភាគទុនិក និងដើមទុន



លោក Yosuke SASAKI
តំណាងភាគទុនិក

AZUMA & Co.,Ltd. ជាភាគទុនិកឯកកម្មសិទ្ធិកាន់ កាប់លើភាគហ៊ុន ១០០% របស់គ្រឹះស្ថាន **ហ្វាតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមសម្តែងនូវសុឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា។

AZUMA & Co.,Ltd. ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ Yosuke SASAKI ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន ១០០% និងមានតួនាទីជា ប្រធាននាយក នៃសហគ្រាស AZUMA & Co.,Ltd.

យើងខ្ញុំមានកិត្តិយសក្រៃលែង ក្នុងនាមជានីតិបុគ្គលនៃសហគ្រាស AZUMA & Co.,Ltd. ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថៃរក្សាអ្នកជំនាន់ក្រោយ ក៏ដូចជាជួយលើកកម្ពស់កម្រិតស្តង់ដារការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗ នៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគោលការណ៍តម្លាភាព ប្រសិទ្ធភាព និងការផ្តល់សេវាហិរញ្ញប្បទានប្រកបដោយនិរន្តរភាពយូរអង្វែងរបស់គ្រឹះស្ថាន **ហ្វាតាចា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំ។



# ◆ រចនាសម្ព័ន្ធ


ម្ចាស់ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
នាយកប្រតិបត្តិ/អភិបាល
ទីប្រឹក្សានាយកប្រតិបត្តិ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
ជំនួយការនាយកប្រតិបត្តិ
ជំនួយការនាយកប្រតិបត្តិ
នាយកដ្ឋានឥណទាន នាយក នាយកដ្ឋាន
នាយកដ្ឋានភតិសន្យា/ទីផ្សារ នាយក នាយកដ្ឋាន
នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋាន
នាយកដ្ឋានហិរញ្ញវត្ថុ នាយិកា នាយកដ្ឋាន
នាយកដ្ឋានព័ត៌មានវិទ្យា នាយក នាយកដ្ឋាន
នាយកដ្ឋានធនធានមនុស្ស/រដ្ឋបាល នាយក នាយកដ្ឋាន
នាយកដ្ឋានច្បាប់/ប្រតិបត្តិតាម នាយក នាយកដ្ឋាន
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
ប្រធានផ្នែកឥណទាន
ប្រធានផ្នែកទីផ្សារ
ប្រធានផ្នែកបេឡាករ
ប្រធានផ្នែកហិរញ្ញវត្ថុ
ប្រធានផ្នែកព័ត៌មានវិទ្យា
មន្ត្រីវិភាគឥណទានជាន់ខ្ពស់
បេឡាធិការជាន់ខ្ពស់
គណនេយ្យករជាន់ខ្ពស់
គណនេយ្យករជាន់ខ្ពស់
មន្ត្រីព័ត៌មានវិទ្យាជាន់ខ្ពស់
មន្ត្រីធនធានមនុស្ស និងរដ្ឋបាលជាន់ខ្ពស់
មន្ត្រីសវនករផ្ទៃក្នុង
មន្ត្រីទីផ្សារ
មន្ត្រីព័ត៌មានវិទ្យា
មន្ត្រីធនធានមនុស្ស និងរដ្ឋបាល
នាយកសាខាការិយាល័យកណ្តាល
នាយកសាខាខណ្ឌទួលគោក
នាយកសាខាខណ្ឌពោធិ៍សែនជ័យ
នាយកសាខាក្រុងច្បារមន

# ក្រុមប្រឹក្សាភិបាល



### លោក ច្រឹក ផល្លី
### ប្រធានក្រុមប្រឹក្សាភិបាល

លោក ច្រឹក ផល្លី កើតនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល ក្រោយមកលោកត្រូវបានតែងតាំង និងទទួលស្គាល់ជាប្រធានក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ លោកមានបទពិសោធន៍ជាង ១៦ឆ្នាំ ខាងផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅក្រុមហ៊ុន Futaba Co., Ltd ក្នុងឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យន័រតុន។ លោកត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ មក។



### លោក Yosuke SASAKI
### សមាជិកក្រុមប្រឹក្សាភិបាល

លោក Yosuke SASAKI កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៨៣ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ ក្រុមហ៊ុន AZUMA & CO., LTD ជាក្រុមហ៊ុនជប៉ុន និងជាម្ចាស់ភាគហ៊ុន ១០០% ដែលតំណាងពេញច្បាប់ដោយលោក Yosuke SASAKI មានតួនាទីជាប្រធាននាយក។

ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន មានគោលគំនិតស្របគ្នាក្នុងការគាំទ្រ និងលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។



## លោក Junichi SASAKI
### សមាជិកក្រុមប្រឹក្សាភិបាល

លោក Junichi SASAKI កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៤៩ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។ លោក Junichi SASAKI បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យតូក្យូ នៅឆ្នាំ១៩៧៥ បច្ចុប្បន្នជាប្រធាន និងជាភាគទុនិក ១០០% នៃក្រុមហ៊ុន FutureBud International Co., Ltd នៃប្រទេសជប៉ុន។



## លោក Hamada MOTOO
### សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក Hamada MOTOO មានសញ្ជាតិជប៉ុន កើតនៅឆ្នាំ១៩៤៨ នៅទីក្រុង KANAGAWA ប្រទេសជប៉ុន។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យពាណិជ្ជកម្ម KOBE (មហាវិទ្យាល័យសេដ្ឋកិច្ច KOBE) ក្នុងឆ្នាំ១៩៧០។ លោកមានបទពិសោធន៍ច្រើនជាង ១៥ឆ្នាំ ក្នុងការវិនិយោគក្រៅប្រទេស និង ២០ឆ្នាំ សម្រាប់ការគ្រប់គ្រងក្រុមហ៊ុន ដែលមានសម្ព័ន្ធភាពនៅក្រៅប្រទេស និង ៥ឆ្នាំ សម្រាប់ការពិគ្រោះយោបល់ និងជួយគម្រោងក្រៅប្រទេសរបស់ក្រុមហ៊ុនខ្នាតតូច និងមធ្យម។



## លោក ង៉ែត សុវណ្ណារ៉ូ
### សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក ង៉ែត សុវណ្ណារ៉ូ មានសញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៥៩ ក្នុងខេត្តតាកែវ ប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់ អនុបណ្ឌិត ផ្នែកកសិកម្ម ពីសាកលវិទ្យាល័យមិត្តភាពនៃប្រជាជនម៉ូស្គូ នៃអាហារូបករណ៍ផ្នែកអនុបណ្ឌិត ផ្តល់ដោយរដ្ឋាភិបាលរុស្ស៊ីក្នុងឆ្នាំ១៩៨៧។ លោកមានបទពិសោធន៍ច្រើនជាង ២៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩២ ក្នុងមុខតំណែងប្រធានគណនេយ្យ និងរយៈពេល ៨ឆ្នាំ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋាន នៃក្រសួងផែនការ។

# គណៈគ្រប់គ្រង



### លោក Junichi SASAKI
### ប្រធាននាយកប្រតិបត្តិ

លោក Junichi SASAKI បានបញ្ចប់ ការសិក្សា ពីសាកលវិទ្យាល័យតូក្យូ នៅក្នុងឆ្នាំ ១៩៧៥ បច្ចុប្បន្ន ជាប្រធាន និង ជាភាគទុនិក ១00% នៃ FutureBud International Co.,Ltd. នៃ ប្រទេសជប៉ុន។



### បណ្ឌិត ចាប រតនា
### ទីប្រឹក្សានាយកប្រតិបត្តិ

បណ្ឌិត ចាប រតនា បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុក បន្ទាប់មកគាត់ក៏មកកាន់តំណែងជា នាយករង នាយកប្រតិបត្តិ នៅខែតុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់បណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រង ការអប់រំនៅសាកលវិទ្យាល័យបៀលប្រាយ។

អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ ការងារយ៉ាងច្រើនដូចជា អ្នកបកប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគំរោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយនឹងមន្ត្រីគ្រប់លំដាប់ថ្នាក់ ក្នុងក្រសួងគ្រប់ខេត្ត-ក្រុង រួមជាមួយនឹងដៃគូអភិវឌ្ឍ អង្គការសហប្រជាជាតិ, IO, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជន ក្នុងផ្នែកអភិវឌ្ឍផែនការថ្នាក់ជាតិ, ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.



## លោក ព្រាប កណ្ដឹង
## ជំនួយការនាយកប្រតិបត្តិ

លោក ព្រាប កណ្ដឹង បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ ( Master of Business Specializing in Finance ) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលពាក់ព័ន្ធទៅនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ការសិក្សាក៏ដូចជាបទពិសោធន៍ការងារបានធ្វើអោយគាត់មានការអភិវឌ្ឍន៍ ជាបន្តបន្ទាប់នូវភាពរីកចំរើននៃអាជីពការងាររបស់គាត់។ មុនពេលគាត់ចូលរួមបំរើការងារជាមួយ **ហ្វូតាចា** លោកមានបទពិសោធន៍ការងារជាច្រើន ពាក់ពន្ធ័ទៅនឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងជានាយក នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។ លោកបានចូលរួមជាមួយ **ហ្វូតាចា** នៅឆ្នាំ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងតួនាទីជាជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួន បី ដូចជានាយកដ្ឋានហិរញ្ញវត្ថុ នាយក ដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស & រដ្ឋបាល។



## លោក អ៊ុំ ពិសិដ្ឋ
## ជំនួយការនាយកប្រតិបត្តិ

លោក អ៊ុំ ពិសិដ្ឋ បានចាប់ផ្ដើមអាជីពការងាររបស់លោកជាមួយ **ហ្វូតាចា** នៅចុងឆ្នាំ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុកគ្រប់គ្រង និងមើលការខុសត្រូវលើនាយកដ្ឋានចំនួនបី គឺ នាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងទូទៅនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបានសញ្ញាប័ត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាលសន្និសិទ និងសិក្ខាសិលាជាច្រើនដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វិស័យអចលនទ្រព្យ ការគ្រប់គ្រង វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១៦ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយនិងមុខតំណែងជាច្រើនដូចជាមន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នាយកគ្រប់គ្រងឥណទាន នាយក នាយកដ្ឋានឥណទាន។ លោកក៏បានចំណាយពេលជាង បីឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ផងដែរ។



## លោក លឹម សំបូរ
## នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក លឹម សំបូរ កើតនៅខែមិថុនា ឆ្នាំ១៩៨១ បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងមុខតំណែងជានាយក នាយកដ្ឋានទីផ្សារ។ បន្ទាប់បម្រើការងាររយៈពេល ២ឆ្នាំ លោកត្រូវបានផ្លាស់ប្តូរមុខតំណែងជា នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយទទួលខុសត្រូវក្នុងការគ្រប់គ្រងរៀបចំចាត់ចែង និងបង្កើតគោលនយោបាយ នីតិវិធីការងារនានាពាក់ព័ន្ធនឹងកិច្ចការធនធានមនុស្ស និងផ្នែករដ្ឋបាល។ នៅមុនពេលចាប់ផ្តើមអាជីពមួយនេះ លោកធ្លាប់មានបទពិសោធន៍ រយៈពេលជាង ១៤ឆ្នាំ បម្រើការងារជាមួយធនាគារធំៗចំនួនពីររួមមាន៖ ធនាគារបរទេសថ្នាក់តំបន់ និងធនាគារក្នុងស្រុកមួយ ដែលមានបណ្តាញប្រតិបត្តិការធំជាងគេផងដែរ។ ជាមួយបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ លោកធ្លាប់បានទទួលខុសត្រូវមុខងារជាច្រើនដូចជា ប្រធានទំនាក់ទំនង ប្រធានផ្នែកឥណទានភតិសន្យា អនុប្រធានផ្នែកឥណទាន និងតួនាទីជាច្រើនទៀត ដែលលោកបានចំណាយពេលជាង ១០ឆ្នាំ ចូលរួមក្នុងសកម្មភាពជាច្រើននៃការលក់ជួរមុខ។ ដោយឡែក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រពីសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារក្នុងឆ្នាំ២០០៨។



## លោក គង់ សារ៉ាត់
## នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក គង់ សារ៉ាត់ ជាជនជាតិខ្មែរ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០១១ រួមទាំងបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យា ផ្នែកអក្សរសាស្ត្រអង់គ្លេសផងដែរ។ ជាមួយនិងអតីតភាពការងារ លោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃធនាគារពាណិជ្ជធំមួយនៅកម្ពុជា ដែលទទួលខុសត្រូវលើផ្នែកប្រព័ន្ធធនាគារស្នូលប្រព័ន្ធ Card និង SWIFT ជាមួយនិងមុខជំនាញបច្ចេកទេសជាច្រើនដូចជាការរៀបចំដំណើរការប្រព័ន្ធធនាគារ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញ Network ប្រកបដោយសុវត្ថិភាព និងការរៀបចំគោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។ នៅដើមឆ្នាំ២០១៦ គាត់បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** ជានាយករងផ្នែកព័ត៌មានវិទ្យា ក្រោយមកបានរយៈពេល ៦ខែបន្ទាប់ គាត់ត្រូវបានតំឡើងតួនាទីជានាយក នាយកដ្ឋានព័ត៌មានវិទ្យា។ គាត់ជាអ្នកចាប់ផ្តើមដំបូងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ Network រៀបចំមជ្ឈមណ្ឌលទិន្នន័យ មជ្ឈមណ្ឌលទិន្នន័យសង្គ្រោះបន្ទាន់ គោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា ក៏ដូចជាគោលនយោបាយសុវត្ថិភាព ទិន្នន័យសម្រាប់គ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីការកកើតដំបូងនៃគ្រឹះស្ថាន។ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ គាត់មានបទពិសោធន៍ផ្នែកព័ត៌មានវិទ្យាជាង ១០ឆ្នាំមកហើយ។



## លោក ផុន សុធា
## នាយក នាយកដ្ឋានឥណទាន

លោក ផុន សុធា បានចូលបម្រើការងារនៅក្នុងគ្រឹះស្ថាន **ហ្វូតាបា** ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧។ មុនពេលដែលគាត់ចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** លោកបានកាន់ការងារក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន អស់រយៈពេល ៧ឆ្នាំជាប់គ្នាក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ក្នុងចន្លោះឆ្នាំ២០១០ ដល់ពាក់កណ្តាលឆ្នាំ២០១៧។ ហើយនៅចន្លោះពីឆ្នាំ២០០៤ រហូតដល់ចុងឆ្នាំ២០១០ លោកជាបុគ្គលិករបស់គ្រឹះស្ថានខ្នាតមធ្យមមួយកន្លែង ដែលការងារដំបូងគាត់បានចូលបម្រើនៅទីនោះ គឺមានតួនាទីជាជំនួយការរដ្ឋបាល / ហិរញ្ញវត្ថុ គាត់ត្រូវបានតែងតាំងជាបន្តបន្ទាប់ រហូតក្លាយជានាយកសាខាដ៏ឆ្នើមរបស់គ្រឹះស្ថានមួយនេះផងដែរ។ បើនិយាយពីប្រវត្តិនៃការសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង ការអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០១១ និងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤។ ក្នុងរយៈពេលជាង ១៤ឆ្នាំ កន្លងមកនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនទាំងក្នុង និងក្រៅប្រទេស ដែលពាក់ព័ន្ធនឹងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារ វិស័យអចលនទ្រព្យ វិស័យធានារ៉ាបរង និងច្បាប់ការងារផ្សេងៗជាច្រើនទៀត។



## លោក ស ភារុំ
## នាយក នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម

លោក ស ភារុំ បានចូលបម្រើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ក្នុងតួនាទីជានាយករងនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។ មុនពេលគាត់ចូលបម្រើការងារនៅ **ហ្វូតាបា** លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន ក្នុងតួនាទីចុងក្រោយជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម ហើយគាត់បានចាប់ផ្តើមការងារក្នុងតួនាទីជាច្រើនជាមួយគ្រឹះស្ថាន ចម្រើន ដែលចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០០៩ ជាមន្ត្រីឥណទាន និងក្លាយជាមន្ត្រីសវនកម្មផ្ទៃក្នុង ក្នុងខែកុម្ភៈ ឆ្នាំ២០១០។ ក្រោយមក គាត់ត្រូវបានតែងតាំងជាប្រធានសាខា នៅខែវិច្ឆិកា ឆ្នាំ២០១០ និងប្តូរទៅ ជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ ក្នុងខែមិថុនា ឆ្នាំ២០១២។ បន្ទាប់មក គាត់ក៏ត្រូវបានដំឡើងទៅជាប្រធានផ្នែកច្បាប់ និងប្រតិបត្តិតាម ក្នុងខែមិថុនា ឆ្នាំ២០១៣ និងជាប្រធាននាយកដ្ឋានច្បាប់ ក្នុងខែមករា ឆ្នាំ២០១៥ ហើយបានទទួលខុសត្រូវក្នុងតួនាទីចុងក្រោយ ជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម។ ហើយគាត់ក៏ធ្លាប់បម្រើការងារនៅសណ្ឋាគារ Feeling Home ជាអ្នកទទួលភ្ញៀវរយៈពេល ១ឆ្នាំ និងធ្វើការជាអ្នកស្ម័គ្រចិត្តជាមួយអង្គការទស្សនៈពិភពលោកនៅស្រុករយៈពេល ៤ឆ្នាំផងដែរ។ គាត់បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យធនធានមនុស្ស។ ក្នុងតួនាទី និងការទទួលខុសត្រូវនោះ គាត់មានបទពិសោធន៍ ក្នុងតួនាទីផ្សេងៗគ្នារយៈពេល ៩ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។



## អ្នកស្រី ប៊ូ រតនា
## នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ

អ្នកស្រី ប៊ូ រតនា កើតនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៨១ នៅទីក្រុងភ្នំពេញ។ អ្នកស្រីបានបញ្ចប់បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីវិទ្យាស្ថានជាតិគ្រប់គ្រង។ នៅថ្ងៃ០១ ខែកក្កដា ឆ្នាំ២០១៦ អ្នកស្រីបានចាប់ផ្តើមចូលរួមបំរើការងារក្នុងគ្រឹះស្ថាន **ហ្វូតាចា** ដោយមានមុខងារជាប្រធានគណនេយ្យ។ បន្ទាប់ពីបម្រើការងារអស់រយៈពេលជាងបីខែ អ្នកស្រីត្រូវបានតែងតាំងជានាយិកាស្តីទី នាយកដ្ឋានហិរញ្ញវត្ថុ ក្នុងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦។ អ្នកស្រីទទួលខុសត្រូវក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ នីតិវិធី ក៏ដូចជាសេចក្តីណែនាំផ្សេងៗ ដែលជាតម្រូវការសម្រាប់នាយកដ្ឋានហិរញ្ញវត្ថុទាំងមូល។ ទន្ទឹមនឹងនេះ អ្នកស្រីបានចូល រួមសហការជាមួយធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ សវនកម្មឯករាជ្យ ក៏ដូចជាក្រសួងពាក់ព័ន្ធផ្សេងៗ ដែលមានការងារទាក់ទងនឹងនាយកដ្ឋានហិរញ្ញវត្ថុ។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ អ្នកស្រីត្រូវបានតម្លើងឋានៈជានាយិកា នាយកដ្ឋានហិរញ្ញវត្ថុ។ មុនពេលចូលរួមបំរើការងារជាមួយ **ហ្វូតាចា** អ្នកស្រីមានបទពិសោធន៍ការងាររយៈពេល ៨ឆ្នាំ ជាប្រធានគណនេយ្យ នៅក្រុមហ៊ុន **ហ្វូតាចា**។ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន អ្នកស្រីមានបទពិសោធន៍ការងារជាង ១០ឆ្នាំ ក្នុងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ។



## លោក ជា សុភ័ក្រ្ត
## នាយក នាយកដ្ឋានប្រតិបត្តិការ

លោក ជា សុភ័ក្រ្ត បានចូលបម្រើការងារនៅក្នុង គ្រឹះស្ថាន **ហ្វូតាចា** ក្នុងតួនាទីជានាយក នាយកដ្ឋានប្រតិបត្តិការចាប់ពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។ មុនពេលចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាចា** លោកបានបម្រើការងារជាអ្នកគ្រប់គ្រងប្រតិបត្តិការក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយនៅកម្ពុជា អស់រយៈពេល ៤ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ នៅចន្លោះឆ្នាំ២០០៧ និង២០១៣ លោកបានធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្នាតមធ្យម ជាមួយនឹងការងារដំបូងរបស់លោកគឺជាគណនេយ្យករ បន្ទាប់មកលោកត្រូវបានតម្លើងតួនាទីជាបន្តបន្ទាប់ជាអ្នកគ្រប់គ្រង គណនេយ្យដ៏ឆ្នើមនៅក្នុងស្ថាប័ននោះ។ លោកទទួលបានបរិញ្ញាបត្រហិរញ្ញវត្ថុ និងគណនេយ្យ នៅសាកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០០៧។ លោកសុភ័ក្រ្ត មានបទពិសោធន៍រួមជាមួយនឹងការអនុវត្តជាក់ស្តែងមុខតំណែងផ្សេងៗក្នុងវិស័យធនាគារ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងសន្និសិទនានា ដែលទាក់ទងទៅនឹងវិស័យមីក្រូហិរញ្ញវត្ថុ និងការងារច្បាប់គ្រប់គ្រងផ្សេងទៀត។



## លោក ហួយ គីមហ៊ាង
## នាយក នាយកដ្ឋានប្រតិបត្តិការ និងទីផ្សារ

លោក ហួយ គីមហ៊ាង បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ក្នុងតួនាទីជា នាយក នាយកដ្ឋានភតិសន្យាហិរញ្ញវត្ថុ។ មុនពេលចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** គាត់បានមានបទពិសោធន៍ច្រើនជាង ១០ឆ្នាំពាក់ព័ន្ធនឹងភតិសន្យាហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ និងការស្រាវជ្រាវទីផ្សារ និងសង្គម ជាមួយនឹងស្ថាប័នស្រាវជ្រាវរបស់អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងក្រុមហ៊ុនសេវាកម្មទូទាត់ប្រាក់។ សម្រាប់ប្រវត្តិនៃការសិក្សា គាត់បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុននៅក្នុងឆ្នាំ២០១០ និងបរិញ្ញាប័ត្រសេដ្ឋកិច្ចពាណិជ្ជកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៥។

# សមិទ្ធផលអាជីវកម្ម

- សមិទ្ធផលឥណទានតាមវិស័យ
- សមិទ្ធផលឥណទានតាមផលិតផល
- ចំណាត់ថ្នាក់ប្រភេទឥណទាន
- ចំណាត់ថ្នាក់ប្រភេទផលិតផល

អបអរសាទរខួប

៥ ឆ្នាំ

ប្រតិបត្តិការ

២០១៦ - ២០២០

# សមិទ្ធផលឥណទានតាមវិស័យ

## ចំនួនគណនី

| វិស័យ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៤ | ២២ | ១៨ |
| ជំនួញ និងពាណិជ្ជកម្ម | ១១១ | ១២៥ | ១២៨ |
| សំណង់ និងទ្រព្យមិនអាចចល័តបាន | ៧៧ | ៩៨ | ១០៣ |
| ការដឹកជញ្ជូន | ៤២ | ៤៣ | ៤០ |
| សេវាកម្ម | ១៥ | ១៤ | ១៧ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៤៣៤ | ៥១៧ | ៤៩៤ |
| ប្រភេទផ្សេងៗទៀត | ៨៧ | ០ | ០ |
| **សរុប** | **៧៨០** | **៨១៩** | **៨០០** |



## ផលប័ត្រឥណទានសរុប

| វិស័យ | ២០១៨ (ដុល្លារអាមេរិក) | ២០១៩ (ដុល្លារអាមេរិក) | ២០២០ (ដុល្លារអាមេរិក) |
|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៧៨.៥០៣ | ២៦២.៥៨២ | ២៨៥.៩១៩ |
| ជំនួញ និងពាណិជ្ជកម្ម | ២.០៣៥.២២៣ | ២.៣១២.២៦១ | ២.៨៥៨.៨២៩ |
| សំណង់ និងទ្រព្យមិនអាចចល័តបាន | ១.៥២៨.២៤៤ | ១.៧១៥.៩៥៥ | ១.៥៥៥.៧៣០ |
| ការដឹកជញ្ជូន | ៦៩៥.៨៩៩ | ៨៥៦.៣៤០ | ៧៤៥.១៣៨ |
| សេវាកម្ម | ៣៥៦.៦៥៩ | ៤៣៤.៣៧៦ | ៥៧៦.០៦៨ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៧.៥០៣.៨៥៥ | ៧.៩៥៨.៩៧៧ | ៨.៣៨៧.៥៣៥ |
| ប្រភេទផ្សេងៗទៀត | ៥០៦.៤២៥ | - | - |
| **សរុប** | **១២.៨០៤.៨០៨** | **១៣.៥៤០.៤៩១** | **១៤.៤០៩.២១៩** |



# សមិទ្ធផលឥណទានតាមផលិតផល

## ចំនួនគណនី

| ផលិតផល | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ឥណទានអាជីវកម្ម | ១៦៤ | ២០១ | ២២៥ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ២៧៤ | ២៤៥ | ២៣៩ |
| ឥណទានកសិកម្ម | ១៥ | ២១ | ២០ |
| ឥណទានគេហដ្ឋាន | ២៤០ | ២៤៤ | ២៣៣ |
| ឥណទានបុគ្គលិក | ៥០ | ៤៨ | ៤៣ |
| ឥណទានសិក្សា | ៦ | ៦ | ៣ |
| ឥណទាននិយោជិត | ៣១ | ៥៤ | ៣៧ |
| **សរុប** | **៧៨០** | **៨១៩** | **៨០០** |



## ផលប័ត្រឥណទានសរុប

| ផលិតផល | ២០១៨ (ដុល្លារអាមេរិក) | ២០១៩ (ដុល្លារអាមេរិក) | ២០២០ (ដុល្លារអាមេរិក) |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៣.២៥៤.១៦៤ | ៤.៣៧២.២៣១ | ៥.៣០៧.៥៧០ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៣.៣៣៦.៤៣៣ | ២.៦២៦.៣៦៣ | ២.៨៤៣.១៩៨ |
| ឥណទានកសិកម្ម | ១៨៥.៩៣៨ | ២១៤.៦៨១ | ២៩១.១៨៤ |
| ឥណទានគេហដ្ឋាន | ៥.៥៨១.៩១៧ | ៥.៨០៩.៧១៤ | ៥.៤៣២.០៧០ |
| ឥណទានបុគ្គលិក | ៣៧៨.៨៩៦ | ៤៣០.៤៨២ | ៤៤៦.៧៧៨ |
| ឥណទានសិក្សា | ២.៩៨៦ | ៣.៨០០ | ១.៩២៥ |
| ឥណទាននិយោជិត | ៦៤.៤៧៤ | ៨៣.២២០ | ៤៦.៤៩៤ |
| **សរុប** | **១២.៨០៤.៨០៨** | **១៣.៥៤០.៤៩១** | **១៤.៤០៩.២១៩** |



## ចំណាត់ថ្នាក់ប្រភេទឥណទាន

### ផលប័ត្រឥណទានសរុប

| ប្រភេទ | ២០១៩ (ដុល្លារអាមេរិក) | ២០២០ (ដុល្លារអាមេរិក) | កំណើន (%) |
|---|---|---|---|
| ឥណទានខ្នាតតូចបំផុត | ៣៤៥.១៧៨ | ២៥៤.១៤៨ | -២៦% |
| ឥណទានខ្នាតតូច | ៣.២៨៥.៩៣៩ | ៤.៣៥០.០៤១ | ៣២% |
| ឥណទានខ្នាតមធ្យម | ៩.៥៧៦.៨២៨ | ៨.៣៩៧.៩២៧ | -១២% |
| ឥណទានខ្នាតធំ | ៣៣២.៥៤៦ | ១.៤០៧.១០៣ | ៣២៣% |
| **សរុប** | **១៣.៥៤០.៤៩១** | **១៤.៤០៩.២១៩** | **៦%** |



# ចំណាត់ថ្នាក់ប្រភេទផលិតផល

## ផលប័ត្រឥណទានសរុប

| ផលិតផល | ២០១៩ (ដុល្លារអាមេរិក) | ២០២០ (ដុល្លារអាមេរិក) | កំណើន (%) |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៤.៣៧២.២៣១ | ៥.៣០៧.៥៧០ | ២១% |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ២.៦២៦.៣៦៣ | ២.៨៨៣.១៩៨ | ១០% |
| ឥណទានកសិកម្ម | ២១៤.៦៨១ | ២៩១.១៨៤ | ៣៦% |
| ឥណទានគេហដ្ឋាន | ៥.៨០៩.៧១៤ | ៥.៤៣២.០៧០ | -៧% |
| ឥណទានបុគ្គលិក | ៤៣០.៤៨២ | ៤៤៦.៧៧៨ | ៤% |
| ឥណទានសិក្សា | ៣.៨០០ | ១.៩២៥ | -៤៩% |
| ឥណទាននិយោជិត | ៨៣.២២០ | ៤៦.៤៩៤ | -៤៤% |
| **សរុប** | **១៣.៥៤០.៤៩១** | **១៤.៤០៩.២១៩** | ៦% |





# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

- ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម
- សវនកម្មផ្ទៃក្នុង

អបអរសាទរខួប
៥ ឆ្នាំ
ប្រតិបត្តិការ
២០១៦ - ២០២០

## ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

និយ័តករ ក្រុមហ៊ុនសវនកម្មឯករាជ្យ និងអ្នកពិគ្រោះយោបល់ ជាផ្នែកមួយនៃការត្រួតពិនិត្យលើប្រតិបត្តិការ របស់ស្ថាប័នពីខាងក្រៅ ដែលអាចបង្ហាញឱ្យឃើញថាគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំណុចខ្វះខាត ហានិភ័យកើតឡើងនានា និងកំណត់ច្បាស់ពីតម្រូវការរបស់ស្ថាប័ន ដែលត្រូវកែលម្អ។ ការគ្រប់គ្រងការប្រតិបត្តិតាម និងហានិភ័យ បានបន្តពង្រឹងការអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ដោយផ្តោតលើការអនុលោមតាមច្បាប់នានា នៃការផ្តល់អាជ្ញាបណ្ណរបស់ធនាគារជាតិនៃកម្ពុជា និងការចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការពង្រីកអាជីវកម្ម និងប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** ប្រកបដោយភាពពេញលេញស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

សមាជិកក្រុមប្រឹក្សាភិបាល បានសម្រេចបង្កើតឱ្យមាននាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ដែលទទួលខុសត្រូវដោយនាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម គឺដើម្បីធានាថាការគ្រប់គ្រងហានិភ័យដែលអាចកើតឡើង និងការប្រតិបត្តិតាមរបស់គ្រឹះស្ថាន **ហ្វូតាបា** មានភាពច្បាស់លាស់ ដោយត្រូវត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យ ទាំងខាងក្នុង និងក្រៅដែលអាចមានការគំរាមកំហែង ឬ ផលប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** និងធានាថាការអនុវត្ត និងនីតិវិធីត្រូវបានអនុវត្តបានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ក្រៅពីនេះលោកក៏ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ ការអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងគោលការណ៍ណែនាំនានា ទាក់ទងនឹងការអនុវត្តច្បាប់របស់គ្រឹះស្ថានរួមមានការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការប្រកាន់ខ្ជាប់នូវការអនុវត្តន៍លើគោលការណ៍ដែលមានស្រាប់ ជាមួយនឹងបញ្ហានានាទាំងខាងក្នុង និងក្រៅពាក់ព័ន្ធនឹងការប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម។ ក្នុងគោលដៅវាស់វែង និងត្រួតពិនិត្យលើសមត្ថភាព និងបទពិសោធន៍ការងាររបស់អ្នកទទួលខុសត្រូវផ្នែកប្រតិបត្តិតាម បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។ បន្ថែមលើនោះទៀត នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវរាយការណ៍ និងសហការប្រតិបត្តិការ ជាមួយនាយកដ្ឋានស៊ើបការណ៍ហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជាផងដែរ។

### - គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គ្រឹះស្ថានបានបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងកម្រិតក្រុមប្រឹក្សាភិបាលដែលមានសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យជាប្រធាន។ នាយក នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ជាអ្នកសម្របសម្រួលដើម្បីពិភាក្សាអំពីរបាយការណ៍ នៃការប្រតិបត្តិតាមជាមួយគ្រប់នាយកដ្ឋាន ឬ គណៈគ្រប់គ្រង និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងភាពពេញលេញនៃការវិភាគហានិភ័យ ប្រតិបត្តិតាមដែលតម្រូវដោយច្បាប់ប្បញ្ញត្តិនានា។ រាល់ហានិភ័យប្រតិបត្តិតាម សំខាន់ៗត្រូវបានបង្ហាញ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដើម្បីជាអនុសាសន៍ក្នុងការប្រតិបត្តិតាម និងដោះស្រាយឱ្យបានទាន់ពេលវេលា។

### - ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំត្រូវធ្វើឡើងយ៉ាងតិច ២ដងក្នុង១ឆ្នាំ ដែលមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក។ គណៈកម្មាធិការនេះ ត្រូវមានសមាជិកយ៉ាងតិច ៣នាក់។ សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានសមាសភាពដូចខាងក្រោម៖



លោក ង៉ែត សុវណ្ណារ៉ូ
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
(ប្រធាន)



លោក YOSUKE SASAKI
សមាជិកក្រុមប្រឹក្សាភិបាល
(សមាជិក)



លោក JUNICHI SASAKI
នាយកប្រតិបត្តិ/អភិបាល
(សមាជិក)



លោក ព្រាប កណ្តឹង
ជំនួយការនាយកប្រតិបត្តិ
(កោះអញ្ជើញ)



លោក អ៊ុំ ពិសិដ្ឋ
ជំនួយការនាយកប្រតិបត្តិ
(កោះអញ្ជើញ)



លោក ស ភារុំ
នាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម
(លេខាធិការ)

- ភារកិច្ច និងការទទួលខុសត្រូវ
  - ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ច្បាប់ និងប្រតិបត្តិតាម ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់
  - ត្រួតពិនិត្យលើការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវការវាយតម្លៃនៃមុខងារប្រតិបត្តិតាម ដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិនានា
  - ពិនិត្យជាប្រចាំនូវបញ្ជីត្រួតពិនិត្យការប្រតិបត្តិតាមផ្ទៃក្នុង ដើម្បីកំណត់ពីហានិភ័យប្រតិបត្តិតាម និងចាត់វិធានការ និងផែនការសកម្មភាពបន្ត ក្នុងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
  - ពិចារណា និងពិនិត្យលើរបាយការណ៍សវនកម្មដែលបានរកឃើញពាក់ព័ន្ធផ្នែកប្រតិបត្តិតាម និងហានិភ័យផ្នែកច្បាប់ដែលកំពុងកើតមានឡើង និងផលប៉ះពាល់នានា
  - ត្រួតពិនិត្យនៃការប្រតិបត្តិតាមប្រកបដោយប្រសិទ្ធភាពលើការអនុវត្តនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា
  - ធានាថា ការបណ្តុះបណ្តាលចាំបាច់ត្រូវបានផ្តល់ជូនដល់គ្រប់បុគ្គលិក និងដើម្បីធានាឱ្យបាននូវការយល់ដឹងនៃសកម្មភាពប្រតិបត្តិតាម រួមទាំងការយល់ដឹងនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងគ្រឹះស្ថាន
  - ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង ត្រូវតែជាផ្នែកមួយឯករាជ្យក្នុងការត្រួតពិនិត្យ និងរាយការណ៍លើការអនុវត្តទូទៅរបស់ស្ថាប័ន។ ផ្នែកសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាចា** ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៧ ទទួលខុសត្រូវដោយប្រធានផ្នែកសវនកម្មផ្ទៃក្នុង ហើយត្រូវបានផ្លាស់ប្តូរ និងបានទទួលស្គាល់ជាថ្មីពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងត្រួតពិនិត្យប្រតិបត្តិការនានានៅក្នុងគ្រឹះស្ថាន **ហ្វូតាចា** ដោយត្រូវអនុវត្តទៅតាមផែនការសវនកម្ម បច្ចុប្បន្នភាពកម្មវិធីសវនកម្ម និងការបណ្តុះបណ្តាលបុគ្គលិក ដែលជាតម្រូវការចាំបាច់ដើម្បីបង្កើនគុណភាពសវនកម្មរបស់ខ្លួន។ តាមគោលការណ៍ និងផែនការរបស់សវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ១ដងក្នុង១ឆ្នាំ ត្រូវចុះធ្វើសវនកម្មនៅការិយាល័យសាខា និងនាយកដ្ឋាននីមួយៗ។ ផ្នែកសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាចា** និងរាយការណ៍ដោយឯករាជ្យ និងដោយផ្ទាល់ទៅគណៈកម្មាធិការសវនកម្មផ្ទៃក្នុងក្នុងកម្រិតក្រុមប្រឹក្សាភិបាល។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០ សវនកម្មផ្ទៃក្នុង ក៏បានរាយការណ៍នូវរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ខ្លួនទៅសមាជិកក្រុមប្រឹក្សាភិបាលពីការអនុវត្តការងារ និងកំហុសឆ្គងនានានៃប្រតិបត្តិការគ្រឹះស្ថានរបស់គណៈគ្រប់គ្រង នាយកដ្ឋាន និងការិយាល័យសាខានីមួយៗ។

ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង គ្រឹះស្ថាន **ហ្វូតាចា** បានបង្កើតគណៈកម្មាធិការចំនួន ២ រួមមាន គណៈកម្មាធិការសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

- គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីធានាអភិបាលកិច្ចសាជីវកម្មប្រកបដោយសុវត្ថិភាព និងត្រូវផ្តល់អំណាចពិសេសចាំបាច់ដែលត្រូវបានកំណត់ក្នុងគោលការណ៍ ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ អំណាចតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មផ្ទៃក្នុងមានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាមាត្រា ៨ នៃប្រកាសលេខ ធ៧-០៨-២១១ ស្តីពីអភិបាលកិច្ចរបស់ធនាគារ និងហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រធានគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ហើយក៏ត្រូវឆ្លើយនឹងសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំ។

- ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំគណៈកម្មាធិការសវនកម្មផ្ទៃក្នុង អាចប្រព្រឹត្តទៅបានក្នុងករណីមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក ឬតាមសំណើរបស់សវនករផ្ទៃក្នុង ឬសវនករឯករាជ្យ (ខាងក្រៅ) ប្រសិនបើចាំបាច់។ កិច្ចប្រជុំត្រូវធ្វើឡើងយ៉ាងតិច ២(ពីរ)ដង ក្នុង ១ឆ្នាំ។

គណៈកម្មាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយមានសមាជិកយ៉ាងតិចបំផុត ៣ រូប។ ប្រធាននៃគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ក្រុមហ៊ុន ហើយគ្រប់សមាជិកទាំងអស់ក៏ត្រូវតែមានភាពឯករាជ្យលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនផងដែរ។ សមាជិកគណៈកម្មាធិការសវនកម្មរួមមានដូចខាងក្រោម:

| | | |
|---|---|---|
| - លោក MOTOO HAMADA | ក្រុមប្រឹក្សាភិបាលឯករាជ្យ | ប្រធាន |
| - លោក JUNICHI SASAKI | នាយកប្រតិបត្តិ/អភិបាល | សមាជិក |
| - លោក ព្រាប កណ្ដឹង | ជំនួយការនាយកប្រតិបត្តិ | កោះអញ្ជើញ |
| - លោក អ៊ុំ ពិសិដ្ឋ | ជំនួយការនាយកប្រតិបត្តិ | កោះអញ្ជើញ |
| - បុគ្គលិកទទួលបន្ទុក | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | សមាជិក/លេខាធិការ |

- ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងអនុម័តទៅលើលក្ខខណ្ឌនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងផែនការប្រចាំឆ្នាំ រួមទាំងគោលបំណង វិសាលភាព និងតារាងកាលវិភាគ
- ពិនិត្យមើលបញ្ហាទាំងឡាយណា ដែលអាចជះឥទ្ធិពលដល់ឯករាជ្យភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យ និងអនុម័តគោលការណ៍ និងនីតិវិធី
- ពិនិត្យមើលការរកឃើញ និងការតាមដានរបស់សវនករផ្ទៃក្នុង រួមទាំងចំណុចសំខាន់ៗ ដែលមិនយល់ស្របគ្នា រវាងគណៈគ្រប់គ្រង និងសវនករផ្ទៃក្នុងពាក់ព័ន្ធនឹងការត្រួតពិនិត្យ
- ធានាថាការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងបើកចំហរមានការចូលរួមក្នុងចំណោមគណៈកម្មាធិការសវនកម្ម សវនករឯករាជ្យ និងសវនកម្មខាងក្នុង
- ផ្ដល់ឱ្យគណៈកម្មាធិការសវនកម្ម អាចចូលជួបសវនករផ្ទៃក្នុង និងប្រធានផ្នែក/នាយក នាយដ្ឋានសវនកម្មផ្ទៃក្នុង ដោយមិនមានការចូលរួមពីគណៈគ្រប់គ្រង
- ប្រាប់ពីការរំពឹងទុករបស់គណៈកម្មាធិការសវនកម្ម ទៅកាន់សវនករផ្ទៃក្នុងឱ្យបានដឹងជាលាយលក្ខណ៍អក្សរ
- ទទួល និងពិនិត្យមើលរបាយការណ៍របស់សវនករផ្ទៃក្នុង ពាក់ព័ន្ធនឹងគុណភាព និងភាពទាន់ពេលវេលាកំណត់
- ពិនិត្យតាមដានការអនុវត្តតាមអនុសាសន៍លើការរកឃើញរបស់សវនករផ្ទៃក្នុង
- តាមដាន និងពិនិត្យឡើងវិញនូវគុណភាពនៃការផ្ដល់សេវាកម្មសវនកម្មផ្ទៃក្នុង។
- វាយតម្លៃដំណើរការរបស់ក្រុមហ៊ុនដែលមាន ដើម្បីតាមដាន និងវាយតម្លៃប្រសិទ្ធភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យមើលការរៀបចំផែនការសកម្មភាពរបស់សវនកម្មផ្ទៃក្នុង សវកម្មឯករាជ្យ និងការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម។

# ផលិតផល ហ្វូតាបា

- ឥណទានអាជីវកម្ម
- ឥណទានគេហដ្ឋាន
- ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន
- ឥណទានកសិកម្ម
- ឥណទានសិក្សា
- ឥណទានបុគ្គលិក
- ឥណទាននិយោជិត



## ផលិតផល និងសេវាកម្ម

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់នូវសេវាហិរញ្ញវត្ថុច្រើនប្រភេទដូចជា ឥណទានអាជីវកម្ម ឥណទានគេហដ្ឋាន ឥណទានកសិកម្ម ឥណទានបុគ្គលិក ឥណទានសម្រាប់ប្រើប្រាស់ ឥណទានសិក្សា និង ឥណទាននិយោជិត ជាមួយនឹងអត្រាការប្រាក់ទាប និងប្រកួតប្រជែងក្នុងទីផ្សារបច្ចុប្បន្ន។





## ឥណទានអាជីវកម្ម

អតិថិជនគោលដៅ :
អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់សម្រាប់ចាប់ផ្តើម ឬ ពង្រីកអាជីវកម្ម ដើម្បីបង្កើនប្រាក់ចំណេញ។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានគេហដ្ឋាន

អតិថិជនគោលដៅ :
អតិថិជនដែលមានតម្រូវការទិញផ្ទះ ឬ សាងសង់ផ្ទះសម្រាប់ស្នាក់នៅ និងប្រកបរបរអាជីវកម្ម។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានសម្រាប់ប្រើប្រាស់

អតិថិជនគោលដៅ :

អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់ ដើម្បីទិញឧបករណ៍សម្ភារៈផ្សេងៗ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានកសិកម្ម

អតិថិជនគោលដៅ :

អតិថិជនដែលមានមុខរបរកសិកម្ម ហើយត្រូវការសាច់ប្រាក់បន្ថែម ដើម្បីវិនិយោគ បម្រើការឲ្យផ្នែកកសិកម្មរបស់ខ្លួន។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានសិក្សា

អតិថិជនគោលដៅ :
សម្រាប់អាណាព្យាបាល ឬ សិស្ស - និស្សិត ដែលខ្វះខាតផ្នែកហិរញ្ញវត្ថុសម្រាប់បង់ថ្លៃសិក្សា។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ

ទំហំឥណទាន : ២០០ ដុល្លារ - ២.០០០ ដុល្លារ

រយៈពេលអតិបរមា : ៥ ឆ្នាំ



## ឥណទានបុគ្គលិក

អតិថិជនគោលដៅ :
សម្រាប់តែបុគ្គលិក ហ្វូតាបា តែប៉ុណ្ណោះ ដែលត្រូវការសាច់ប្រាក់ ដើម្បីគាំទ្រដល់ការរស់នៅប្រចាំថ្ងៃ។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល ឬដុល្លារ

ទំហំឥណទាន : ២៤ ដង ឬ ៤៨ ដង នៃប្រាក់ខែមូលដ្ឋាន

រយៈពេលអតិបរមា : ១៥ ឆ្នាំ



## ឥណទាននិយោជិត

អតិថិជនគោលដៅ ៖
សម្រាប់បុគ្គលទូទៅដែលមានបំណងចង់ទិញម៉ូតូ សម្ភារៈប្រើប្រាស់ រៀបការ និងផ្សេងៗ តែក្នុងលក្ខខណ្ឌស្របច្បាប់។

ប្រភេទរូបិយប័ណ្ណ ៖ ប្រាក់រៀល ឬដុល្លារ

ទំហំឥណទាន ៖ ២០.០០០.០០០ រៀល ឬ ៥.០០០ដុល្លារ

រយៈពេលអតិបរមា ៖ ២ ឆ្នាំ

| លក្ខណៈសម្បត្តិរបស់អ្នកខ្ចី | ឯកសារតម្រូវ |
|---|---|
| - ជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ទៅ ៦៥ឆ្នាំ<br>- មានទីលំនៅអចិន្ត្រៃយ៍ ស្ថិតក្នុងតំបន់ប្រតិបត្តិការរបស់ **ហ្វូតាបា** ។<br>- មានប្រវត្តិល្អនៅក្នុងសង្គម<br>- មានមុខរបរ ឬ អាជីវកម្មស្របច្បាប់<br>- មានទ្រព្យធានាត្រឹមត្រូវ | - អត្តសញ្ញាណប័ណ្ណ ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ សំបុត្រកំណើត ឬ លិខិតឆ្លងដែន . . . ។ល។<br>- ឯកសារទ្រព្យធានា ( ប្លង់រឹង ឬ ប្លង់ទន់ )<br>- ឯកសារផ្សេងៗ ពាក់ព័ន្ធនឹងប្រភពចំណូល |

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

- ការបណ្តុះបណ្តាលខាងក្នុង
- ការបណ្តុះបណ្តាលខាងក្រៅ

អបអរសាទរខួប

៥ ឆ្នាំ

ប្រតិបត្តិការ

២០១៦ - ២០២០

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

ឆ្នាំ២០២០នេះ ប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូល បានទទួលរងនូវផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ បង្កការភ័យខ្លាចយ៉ាងខ្លាំងបំផុត ដែលរំខានដល់ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងសង្គម។ ស្ថិតក្នុងស្ថានភាពដ៏លំបាកនេះក្រសួងសុខាភិបាល បានដាក់ចេញនូវសេចក្តីណែនាំជាបន្តបន្ទាប់ ស្តីពីការអនុវត្តវិធានការសុវត្ថិភាពឱ្យបានម៉ឺងម៉ាត់ ហើយក្រសួងការងារក៏បានចេញសេចក្តីប្រកាសផងដែរ ដល់គ្រប់ក្រុមហ៊ុន សហគ្រាសទាំងអស់យកចិត្តទុកដាក់អនុវត្តត្រឹមត្រូវតាមវិធាននានា ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ គណៈគ្រប់គ្រងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចាត់វិធានការរឹតត្បិតការជួបជុំមនុស្សច្រើន ដោយគោរពប្រតិបត្តិតាមទាំងស្រុងនូវវិធានសុវត្ថិភាព ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត។ ទោះជាយ៉ាងណា ការអភិវឌ្ឍសមត្ថភាពបុគ្គលិកគឺជាកិច្ចការចាំបាច់ផងដែរសម្រាប់ថ្នាក់ដឹកនាំរបស់ **ហ្វូតាបា** ដែលតែងឆ្លៀតយកពេលវេលាដ៏សាកសម ដើម្បីផ្តល់ការហ្វឹកហ្វឺន ពង្រឹងការយល់ដឹងដល់បុគ្គលិក ក្នុងគោលដៅលើកកម្ពស់សមត្ថភាព ជំនាញ និងជំរុញលើកទឹកចិត្តឱ្យបំពេញការងារប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងស្ថានការវិវត្តន៍ជាក់ស្តែង។ ជាលទ្ធផលវគ្គបណ្តុះបណ្តាលនានា ត្រូវបានរៀបចំផ្តល់ជូនបុគ្គលិកចូលថ្មី និងបុគ្គលិកកំពុងបម្រើការងារគ្រប់ផ្នែកទាំងអស់ ក្នុងលក្ខខណ្ឌពេលមានតម្រូវការចាំបាច់បំផុតតែប៉ុណ្ណោះ ដែលត្រូវបានគោរពអនុវត្ត យ៉ាងខ្ជាប់ខ្ជួនតាមវិធានសុវត្ថិភាព របស់ក្រសួងការងារ និងក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

### - ការបណ្តុះបណ្តាលខាងក្នុង

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានផ្តល់ការហ្វឹកហ្វឺន បណ្តុះបណ្តាលខាងក្នុងមានចំនួនសរុប ២៤លើក ដែលក្នុងនោះរួមមានការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី និងបុគ្គលិកំពុងបម្រើការងារផងដែរ។









សកម្មភាពបណ្តុះបណ្តាលផ្នែកខាងក្នុង



សកម្មភាពបណ្តុះបណ្តាលផ្នែកខាងក្នុង



សកម្មភាពបណ្តុះបណ្តាលផ្នែកខាងក្នុង



សកម្មភាពបណ្តុះបណ្តាលផ្ទៃកខាងក្នុង

### - ការបណ្តុះបណ្តាលខាងក្រៅ

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបន្តអភិវឌ្ឍចំណេះដឹងជំនាញថ្មីៗបន្ថែមទៀតដល់បុគ្គលិក ថ្នាក់ដឹកនាំរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានជំរុញលើកទឹកចិត្ត ដោយចាត់បញ្ជូនថ្នាក់គ្រប់គ្រង និងបុគ្គលិកជំនាញពាក់ព័ន្ធ ឱ្យចូលរួមវគ្គបណ្តុះបណ្តាលខាងក្រៅជាបន្តបន្ទាប់ តាមរយៈប្រព័ន្ធអ៊ីនធើណេត (Online)។

ជាលទ្ធផល ក្នុងឆ្នាំ២០២០នេះ ថ្នាក់គ្រប់គ្រង និងបុគ្គលិករបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចូលរួមវគ្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅខាងក្រៅមានចំនួនសរុប ១៥លើក។

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់

អបអរសាទរខួប
៥ ឆ្នាំ
ប្រតិបត្តិការ
២០១៦ - ២០២០

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមធ្វើការបង្ហាញ ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុជាសាធារណៈទៅសហគ្រាសធុនតូច និង មធ្យម ជាឯកត្តជន តាមរយៈការិយាល័យកណ្តាល និងសាខា៣ ផ្សេងទៀតដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ និង ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនោះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | | ២០២០ | | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ២.៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ៥៩៩.៣៥២ | ២.៤៤៣.៥៥៨ | ៦០៤.៦៤៨ | ២.៤៥០.០៣៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១២២.២៩០) | (៤៩៨.៥៧៦) | (១៣៩.៨៣២) | (៥៦៦.៥៩៩) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ៤៧៧.០៦២ | ១.៩៤៤.៩៨២ | ៤៦៤.៨១៦ | ១.៨៨៣.៤៣៥ |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

ដើមទុនចុះបញ្ជី និងដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មានចំនួន ៧.០០០.០០០ ដុល្លារអាមេរិក (២០១៨: ៧.០០០.០០០ ដុល្លារអាមេរិក) ដែលក្នុងនោះក្នុងមួយភាគហ៊ុនស្មើនឹង ១.០០០ ដុល្លារអាមេរិក។ ភាគហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ទី ១៤។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និង ឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យមានការលុបបំបាត់ចោលឥណទានអាក្រក់ ឬការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណហិរញ្ញវត្ថុនេះមានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់ វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការ អាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក ច្រឹក ផល្លី | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក យូសូកេ សាសាគី | អភិបាល |
| លោក ជូនីជី សាសាគី | អភិបាល |
| លោក ម៉ូតូ ហាម៉ាដា | អភិបាលឯករាជ្យ |
| លោក ង៉េត សុវណ្ណារ៉ូ | អភិបាលឯករាជ្យ |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬ ដោយប្រយោល នៅក្នុងការិយបរិច្ឆេទនេះឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃទៀយ។ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយកុម្រហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMEs ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗ ទាំងឡាយដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី ១០ ដល់ ៥០ ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី ១០ ដល់ ៥០។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំឯករាជ្យភាពពីក្រុមហ៊ុន តាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌ ទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ការទាញចំណាប់អារម្មណ៍លើបញ្ហា - ព័ត៌មានប្រៀបធៀប

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ ២៥ នៃរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញថា ព័ត៌មានប្រៀបធៀប ដែលបានបង្ហាញនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងសម្រាប់ការិយបរិច្ឆេទដែលបញ្ចប់ត្រូវបានកំណត់ឡើងវិញ។ មតិសវនកម្មរបស់យើងខ្ញុំមិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ថារបាយការណ៍នោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ១ ដល់ទី ៥ ចំណែកឯរបាយការណ៍ប្រចាំឆ្នាំ របស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។

មតិរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើការអានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចអ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាព

អាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យ ដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។

យើងខ្ញុំក៏បាន៖

. ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោល ដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

. ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធី សវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

. ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

. ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។

. វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមានជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្តរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត




ហេង សិតា
នាយកគ្រប់គ្រង
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សំគាល់២.៤) | ២០១៩<br>ដុល្លារអាមេរិក | ២០១៩<br>ពាន់រៀល<br>(កំណត់សំគាល់២.៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ២៣.១១៥ | ៩៣.៥០០ | ៥៤.២០០ | ២២០.៨៦៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៥ | ៣៥៤.១៧៣ | ១.៤៣២.៦៣០ | ៣៥២.៤០៤ | ១.៤៣៦.០៤៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ | ៦ | ២៧០.១៨៩ | ១.០៩២.៩១៥ | ៧១១.៥៥១ | ២.៨៩៩.៥៧០ |
| ឥណទានផ្តល់ដល់អតិថិជនសុទ្ធ | ៧ | ១៤.២៣៨.៩៥៩ | ៥៧.៥៩៦.៥៨៩ | ១៣.៤១៧.៧១៤ | ៥៤.៦៧៧.១៨៥ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ១៣០.៨៤២ | ៥២៩.២៥៦ | ២១៧.៥៨៩ | ៨៨៦.៦៧៤ |
| ទ្រព្យ និងបរិក្ខារ | ៩ | ១០៧.០៦៨ | ៤៣៣.០៩០ | ១៤៨.០៦៣ | ៦០៣.៣៥៧ |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | ១១.១ | - | - | ១៦.៦១៣ | ៦៧.៦៩៨ |
| **ទ្រព្យសកម្មសរុប** | | ១៥.១២៤.៣៤៦ | ៦១.១៧៧.៩៨០ | ១៤.៩១៨.១៣៤ | ៦០.៧៩១.៣៩៥ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១០ | ៦៣.១៨៩ | ២៥៥.៦០០ | ១៨៩.៩០៥ | ៨១០.៥៣៧ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១១.២ | ៧៥.៨៩៤ | ៣០៦.៩៩១ | ១០៣.០៧០ | ៤២០.០១០ |
| បុរេប្រទានពីភាគទុនិក | ១២ | ១.៣៩០.០០០ | ៥.៦២២.៥៥០ | ១.៣៩០.០០០ | ៥.៦៦៤.២៥០ |
| ប្រាក់កម្ចី | ១៣ | ៥.៥៣០.៥១៣ | ២២.៣៧០.៩២៥ | ៥.៦៥០.៩៣៧ | ២៣.០២៧.៥៦៨ |
| ពន្ធពន្យារជាបំណុលសុទ្ធ | ១១.១ | ១២.៤៦៦ | ៥០.៤២៥ | - | - |
| **បំណុលសរុប** | | ៧.០៧២.០៦២ | ២៨.៦០៦.៤៩១ | ៧.៣៤២.៩១២ | ២៩.៩២២.៣៦៥ |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | ៧.០០០.០០០ | ២៨.០០០.០០០ | ៧.០០០.០០០ | ២៨.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៥ | ៣០០.៨៥៦ | ១.២១៦.៩៦៣ | ១៤៨.៤៥៦ | ៦០៤.៩៥៨ |
| ប្រាក់ចំណេញរក្សាទុក | | ៧៥១.៤២៨ | ៣.០៥៣.៥២៧ | ៤២៦.៧៦៦ | ១.៧២៩,៥៧៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៣០០.៩៩៩ | - | ៥៣៤.៤៩៧ |
| មូលធនសរុប | | ៨.០៥២.២៨៤ | ៣២.៥៧១.៤៨៩ | ៧.៥៧៥.២២២ | ៣០.៨៦៩.០៣០ |
| **បំណុល និងមូលធនសរុប** | | ១៥.១២៤.៣៤៦ | ៦១.១៧៧.៩៨០ | ១៤.៩១៨.១៣៤ | ៦០.៧៩១.៣៩៥ |

# របាយការណ៍លទ្ធផលលម្អិត

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សំគាល់ ២.៤) | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល (កំណត់សំគាល់ ២.៤) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១៦ | ១.៨៨៩.២៦០ | ៧.៧០២.៥១៣ | ១.៨១២.២៩៧ | ៧.៣៤៣.៤២៧ |
| ចំណាយលើការប្រាក់ | ១៧ | (១៣៩.៧២២) | (៥៦៩.៦៤៧) | (៩១.០០៥) | (៣៦៨.៧៥២) |
| ចំណូលពីការប្រាក់សុទ្ធ | | ១.៧៤៩.៥៣៨ | ៧.១៣២.៨៦៦ | ១.៧២១.២៩២ | ៦.៩៧៤.៦៧៥ |
| ចំណូលផ្សេងៗ | ១៨ | ៧៣.៥៣១ | ២៩៩.៧៨៦ | ៥៨.៣៥១ | ២៣៦.៤៣៨ |
| ចំណូលប្រតិបត្តិការសរុប | | ១.៨២៣.០៦៩ | ៧.៤៣២.៦៥២ | ១.៧៧៩.៦៤៣ | ៧.២១១.១១៣ |
| ចំណាយទូទៅ និងរដ្ឋបាល | ១៩ | (១.១២៣.៩៧៧) | (៤.៥៨២.៤៥៤) | (១.១៧៣.៩៤៦) | (៤.៧៥៦.៨២៩) |
| សំវិធានធនលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | ៧ | (៩៩.៧៤០) | (៤០៦.៦៤០) | (៩៦៧) | (៣.៩១៨) |
| សំវិធានធនលើប្រាក់តម្កល់នៅធនាគារ | | - | - | (៨២) | (៣៣២) |
| ប្រាក់ចំណេញមុនដកពន្ធ | | ៥៩៩.៣៥២ | ២.៤៤៣.៥៥៨ | ៦០៤.៦៤៨ | ២.៤៥០.០៣៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១១.៣ | (១២២,២៩០) | (៤៩៨.៥៧៦) | (១៣៩.៨៣២) | (៥៦៦.៥៩៩) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | ៤៧៧.០៦២ | ១.៩៤៤.៩៨២ | ៤៦៤.៨១៦ | ១.៨៨៣.៤៣៥ |
| លទ្ធផលលម្អិតផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (២៣៣.៤៩៨) | - | ៤០៨.៤៩៧ |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | ៤៧៧.០៦២ | ១.៧១១.៤៨៤ | ៤៦៤.៨១៦ | ២.២៩១.៩៣២ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | ដើមទុន ដុល្លារអាមេរិក | ដើមទុន ពាន់រៀល (កំណត់សំគាល់ ២.៤) | ទុនបម្រុងតាមបទប្បញ្ញត្តិ ដុល្លារអាមេរិក | ទុនបម្រុងតាមបទប្បញ្ញត្តិ ពាន់រៀល (កំណត់សំគាល់ ២.៤) | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ពាន់រៀល (កំណត់សំគាល់ ២.៤) | លម្អៀងពីការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | លម្អៀងពីការប្តូររូបិយប័ណ្ណ ពាន់រៀល (កំណត់សំគាល់ ២.៤) | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ៧.០០០.០០០ | ២៨.០០០.០០០ | ១១៩.៧៨០ | ៤៨១.២៧៦ | (៩.៣៧៤) | (៣៧.៦៦៥) | - | ១២៦.០០០ | ៧.១១០.៤០៦ | ២៨.៥៦៩.៦១១ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ៤៦៤.៨១៦ | ១.៨៨៣.៤៣៥ | - | - | ៤៦៤.៨១៦ | ១.៨៨៣.៤៣៥ |
| ការផ្ទេរ | - | - | ២៨.៦៧៦ | ១១៦.១៩៥ | (២៨.៦៧៦) | (១១៦.១៩៥) | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៧.៤៨៧ | - | - | - | ៤០៨.៤៩៧ | - | ៤១៥.៩៨៤ |
| សរុបលទ្ធផលលម្អិតសម្រាប់ ការិយបរិច្ឆេទ | - | - | ២៨.៦៧៦ | ១២៣.៦៨២ | ៤៣៦.១៤០ | ១.៧៦៧.២៤០ | - | ៤០៨.៤៩៧ | ៤៦៤.៨១៦ | ២.២៩៩.៤១៩ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | ៧.០០០.០០០ | ២៨.០០០.០០០ | ១៤៨.៤៥៦ | ៦០៤.៩៥៨ | ៤២៦.៧៦៦ | ១.៧២៩.៥៧៥ | - | ៥៣៤.៤៩៧ | ៧.៥៧៥.២២២ | ៣០.៨៦៩.០៣០ |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៧.០០០.០០០ | ២៨.០០០.០០០ | ១៤៨.៤៥៦ | ៦០៤.៩៥៨ | ៤២៦.៧៦៦ | ១.៧២៩.៥៧៥ | - | ៥៣៤.៤៩៧ | ៧.៥៧៥.222 | ៣០.៨៦៩.០៣០ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ៤៧៧.០៦២ | ១.៩៤៤.៩៨២ | - | - | ៤៧៧.០៦២ | ១.៩៤៤.៩៨២ |
| ការផ្ទេរ | - | - | ១៥២.៤០០ | ៦២១.០៣០ | (១៥២.៤០០) | (៦២១.០៣០) | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (៩.០២៥) | - | - | - | (២៣៣.៤៩៨) | - | (២៤២.៥២៣) |
| សរុបលទ្ធផលលម្អិតសម្រាប់ ការិយបរិច្ឆេទ | - | - | ១៥២.៤០០ | ៦១២.០០៥ | ៣២៤.៦៦២ | ១.៣២៣.៩៥២ | - | (២៣៣.៤៩៨) | ៤៧៧.០៦២ | ១.៧០២.៤៥៩ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៧.០០០,០០០ | ២៨.០០០.០០០ | ៣០០.៨៥៦ | ១.២១៦.៩៦៣ | ៧៥១.៤២៨ | ៣.០៥៣.៥២៧ | - | ៣០០.៩៩៩ | ៨.០៥២.២៨៤ | ៣២.៥៧១.៤៨៩ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ២.៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | ៤៧៧.០៦២ | ១.៩៤៤.៩៨២ | ៤៦៤.៨១៦ | ១.៨៨៣.៤៣៥ |
| **និយ័តភាពលើ:** | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១២២.២៩០ | ៤៩៨.៥៧៦ | ១៣៩.៨៣២ | ៥៦៦.៥៩៩ |
| ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | ៩៩.៧៤០ | ៤០៦.៦៤០ | ៩១២ | ៣.៦៩៥ |
| រំលស់ | ៥៣.៩១៥ | ២១៩.៨១១ | ៥៥.៩៦៦ | ២២៦.៧៧៤ |
| (ចំណេញ)/ខាតលើការលក់ទ្រព្យ និងបរិក្ខារ | (៤៥) | (១៨៣) | ១០៩ | ៤៤២ |
| | ៧៥២.៩៦២ | ៣.០៦៩.៨២៦ | ៦៦១.៦៣៥ | ២.៦៨០.៩៤៥ |
| បម្រែបម្រួល ៖ | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (៩២០.៩៨៥) | (៣.៧៥៤.៨៥៦) | (៦៥៤.៦៣២) | (២.៦៥២.៥៦៩) |
| ទ្រព្យសកម្មផ្សេងៗ | ៨៦.៧៤៧ | ៣៥៣.៦៦៨ | (៩៤.៩៨០) | (៣៨៤.៨៥៩) |
| បំណុលផ្សេងៗ | (១៣៥.៧១៦) | (៥៥៣.៣១៤) | (២០.៨១៨) | (៨៤.៣៥៥) |
| | (២១៦.៩៩២) | (៨៨៤.៦៧៦) | (១០៨.៧៩៥) | (៤៤០.៨៣៨) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (១២០.៣៨៧) | (៤៩០.៨១៨) | (១១៤.៤៥៥) | (៤៦៣.៧៧២) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | (៣៣៧.៣៧៩) | (១.៣៧៥.៤៩៤) | (២២៣.២៥០) | (៩០៤.៦១០) |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (១៣.០៧៥) | (៥៣.៣០៧) | (៩.៦៦០) | (៣៩.១៤២) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | ២០០ | ៨១៥ | ៦០ | ២៤៣ |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (១២.៨៧៥) | (៥២.៤៩២) | (៩.៦០០) | (៣៨.៨៩៩) |
| | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ប្រាក់កម្ចីពីភាគទុនិក | - | - | ៤០០.៤០០ | ១.៦២២.៤២១ |
| ការទូទាត់សងប្រាក់កម្ចីពីភាគទុនិក | - | - | (២០០.០០០) | (៨១០.៤០០) |
| ប្រាក់កម្ចីពីធនាគារ | - | - | ៤៩០.៧៩៨ | ១.៩៨៨.៧១៣ |
| ការទូទាត់សងប្រាក់កម្ចីពីធនាគារ | (១២០.៤២៤) | (៤៩០.៩៦៩) | - | - |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន | (១២០.៤២៤) | (៤៩០.៩៦៩) | ៦៩១.១៩៨ | ២.៨០០.៧៣៤ |
| | | | | |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (៤៧០.៦៧៨) | (១.៩១៨.៩៥៥) | ៤៥៨.៣៤៨ | ១.៨៥៧.២២៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី១ ខែមករា** | ៧៦៨.១៥៥ | ៣.១៣០.២៣១ | ៣០៩.៨០៧ | ១.២៤៤.៨០៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៧.៩៨១) | - | ២៨.២០២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី៣១ ខែធ្នូ (កំណត់សម្គាល់ ២០) | ២៩៧.៤៧៧ | ១.២០៣.២៩៥ | ៧៦៨.១៥៥ | ៣.១៣០.២៣១ |

# ដៃគូសហប្រតិបត្តិការណ៍

## ដៃគូ

# ម្ចាស់ជំនួយ

AZUMA & CO., LTD.

PPCBank

០៧០ ៣១៩ ៣៣៣

អាសយដ្ឋាន៖
អគារលេខ ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២២៤ ៣៣៣ ទូរសារ:  ០២៣ ២២២ ១៣១
អ៊ីម៉ែល: info@futabamfi.com.kh
ហ្វេសបុក: Futaba Microfinance Plc.